# ទំនុកសរសើរដំកើង

គេអាចនិយាយបានថា មូលដ្ឋាននៃទំនុកដំកើងគឺបង្ហាញពី គោលបំណងរបស់មនុស្សដែលមាន ហើយរស់នៅ គឺដើម្បីសរសើរដំកើងព្រះអម្ចាស់។ អ្នកទំនុកដំកើងបាននិពន្ធទំនុកដំកើងនេះឡើង ដើម្បីសរសើរដំកើងព្រះអម្ចាស់។

ឈ្មោះកណ្ឌទំនុកដំកើង ត្រូវបានដាក់ជាភាសាហេព្រើ ឈ្មោះថា "tehillim" (ការសរសើរ)។ ទុកណាជាទំនុកតម្អូញ មានច្រើនជាងទំនុកសរសើរនៅក្នុងសៀវភៅទី១ដល់៣ក្ដី ក៏ទំនុកសរសើរមានយ៉ាងច្រើននៅក្នុងសៀវភៅទី៤និង៥។ ការដើរពីទំនុកតម្អូញ ទៅកាន់ការសរសើរ វាហាក់ដូចជាការដែលចងក្រងដោយមានបំណងច្បាស់លាស់នៅក្នុងកណ្ឌទំនុកដំកើង។ ការសរសើរគឺជាទិសដៅ របស់កណ្ឌទំនុកដំកើងទាំងមូលឆ្ពោះទៅរក។ មានការសរសើរនៅចុងបញ្ចប់នៃសៀវភៅនីមួយៗ៖ ទំនុកដំកើង ៤១:១៣; ៧២:១៨-១៩; ៨៩:៥២; ១០៦:៤៨; និង១៤៦-១៥០។ តាមលោក Hans-Joachim Kraus បានផ្ដល់បញ្ជីនៃទំនុកសរសើរដំកើងមាន ទំនុកដំកើង ៨, ១៩ក, ២៩, ៣៣, ៤៧, ៦៥, ៦៦ក, ៦៨, ៩៣, ៩៦, ៩៧, ៩៨, ៩៩, ១០០, ១០៤, ១០៥, ១០៦, ១១១, ១១៣, ១១៤, ១១៧, ១៣៤, ១៣៥, ១៣៦, ១៤៥, ១៤៦, ១៤៧, ១៤៨, ១៤៩, ១៥០។

ទំនុកសរសើរអាចមានការបែងចែកជាពីរផ្នែក៖

១. ចំរៀងដែលអាចខុសគ្នាដោយសារទម្រង់

- ១.ក ចំរៀងបញ្ជាសរសើរ ដូចមានគំរូពីនិក្ខមនំ ១៥២១។ ហេតុផលនៃការសរសើរដំកើង ត្រូវបានប្រើពាក្យ "ពីព្រោះ (ព្រោះ)"។ ទំនុកដំកើងទាំងនោះ មានទំនុកដំកើង ៩៦, ៩៨, ១០០, និង១៣៦។
- ១.ខ ចំរៀងចូលរួម មានគំរូឧទាហរណ៍ដូចនៅក្នុង អេសាយ ៤០-៥៥។
- ១.គ ចំរៀងបុគ្គលម្នាក់ៗ ដូចមានគំរូឧទាហរណ៍ នៅក្នុងទំនុកដំកើង ៨ និង ១០៤។

២. ចំរៀងដែលអាចខុសគ្នាដោយផ្ទៃរឿង មិនមែនទម្រង់ទេ

- ២.ក ទំនុកសរសើរពីការបង្កើតរបស់ព្រះ៖ ទំនុកដំកើង ៨, ១៩ក, ៣៣, ១០៤, និង១៣៦។
- ២.ខ ទំនុកព្រះយេហូវ៉ាជាព្រះមហាក្សត្រ៖ ទំនុកដំកើង ៤៧, ៩៣, ៩៦, ៩៧, ៩៨, និង ៩៩។
- ២.គ ទំនុកប្រមូលផល៖ ទំនុកដំកើង ៦៥ និង១៤៥។
- ២.ឃ ទំនុកប្រវត្តិសាស្ត្រ៖ ទំនុកដំកើង ១០៥, ១០៦, ១១៤, ១៣៥, និង ១៣៦។
- ២.ង ទំនុកទ្វារចូល៖ ទំនុកដំកើង ២៤, ៩៥, និង១០០។

វាមានការលំបាកក្នុងការស្វែងយល់ឲ្យច្បាស់ពីស្ថានភាពជីវិតនៃទំនុកដំកើងទាំងនោះ។ ទំនុកដំកើងខ្លះប្រហែលជាត្រូវបានសរសេរជាពិសេស សំរាប់ការថ្វាយបង្គំនៅព្រះវិហារ (ឧ. ទំនុកដំកើង ១៣៦) នៅពេលទំនុកដំកើងដទៃទៀតគឺជាការសំដែងពីការអរព្រះគុណព្រះចំពោះទង្វើដ៏អស្ចារ្យ និងសេចក្ដីល្អរបស់ព្រះ (ប្រហែលជា

ទំនុកដំកើង ៨) ហើយក្រោយមកទៀតត្រូវបានប្រើនៅក្នុងការថ្វាយបង្គំព្រះនៅក្នុងព្រះវិហារ ប្រសិនបើទំនុកដំកើងនោះ ត្រូវបានបញ្ចូលក្នុងការថ្វាយបង្គំនៅព្រះវិហារ។ យើងមិនអាចសន្មតទាំងអស់បានថាគ្រប់ទំនុកដំកើងទាំងអស់ត្រូវបានប្រើនៅក្នុងព្រះវិហារនោះទេ។ និយាយបែបនេះ ទំនុកដំកើងគឺជាសៀវភៅចំរៀងមួយក្បាល របស់ព្រះវិហារ ប៉ុន្តែមិនមានគោលបំណងដូចសៀវភៅចំរៀងនាសម័យសព្វថ្ងៃ ដែលចងក្រងមកដើម្បីច្រៀងសរសើរនៅក្នុងព្រះវិហារនោះទេ។ កណ្ឌទំនុកដំកើងគឺជាសៀវភៅនៃការប្រមូលផ្តុំសំរាប់ការថ្វាយបង្គំរួម ឬឯកជនម្នាក់ៗ។ ទំនុកដំកើងត្រូវបានសរសេរឡើងសំរាប់ប្រើប្រាស់ម្នាក់ៗផ្ទាល់ខ្លួន និងសំរាប់ប្រើប្រាស់រួម ដូចនេះទំនុកដំកើងអាចប្រើពីឯកជនទៅជាសហភាព និងពីសហភាពទៅជាឯកជន។

ផ្ទៃរឿងសំខាន់ៗនៃទំនុកសរសើរដំកើង

១. ការបង្កើត

១.ក ការបង្កើតដោយព្រះបន្ទូលបញ្ជា

បន្ទាប់ពីអ្នកទំនុកដំកើងបានកោះហៅព្រះអាទិត្យ ព្រះចន្ទ ផ្កាយ ផ្ទៃមេឃ និងទឹកឲ្យសរសើរដំកើងព្រះនោះគាត់បានចងចាំឡើងវិញថា៖ "ដ្បិតទ្រង់បានចេញបង្គាប់ ហើយរបស់ទាំងនោះបានកើតមក ទ្រង់បានតាំងរបស់ទាំងនោះឲ្យនៅអស់កល្បជានិច្ច ទ្រង់បានដាក់ច្បាប់ហើយ ជាច្បាប់ ដែលរបស់ទាំងនោះនឹងមិនប្រព្រឹត្តរំលងឡើយ" (ទំនុកដំកើង ១៤៨:៥ក-៦)។

ព្រះបន្ទូលនៃព្រះបាននាំមកនូវការបង្កើត នេះគឺជាអ្វីដែលអ្នកទំនុកដំកើងបាននិយាយម្តងទៀតនៅទំនុកដំកើង ៣៣:៦៖

> "ផ្ទៃមេឃបានកើតមក ដោយ*សារព្រះបន្ទូល*ព្រះយេហូវ៉ា
> ហើយពួកបរិវារនៅលើនោះ បានកើតដោយសារ*ខ្យល់ពីព្រះឱស្ឋ*ទ្រង់"។

ដូចគ្នានេះយើងឃើញមានពាក្យ "មានបន្ទូល" ត្រូវបានដាក់ឲ្យស៊ីគ្នានិងពាក្យ "បង្គាប់" ដែលបង្កើតបានជាអត្ថន័យដូចគ្នាចំពោះគំនិតពីរ (ទំនុកដំកើង ៣៣:៩)៖

> ដ្បិតទ្រង់គ្រាន់តែ*មានបន្ទូល* នោះក៏កើតមានដូច្នោះ
> ទ្រង់បាន*បង្គាប់* នោះក៏មាននៅ។

១.ខ ការបង្កើតដោយទង្វើ

លក្ខណៈទីពីរនៃការពណ៌នាសកម្មភាពការបង្កើតរបស់ព្រះ គឺដោយទង្វើ ហើយទំនុកដំកើងក៏បាននិយាយពីការនេះផងដែរ។ ព្រះអម្ចាស់បានធ្វើឲ្យមានផ្កាយ ហើយបានហៅផ្កាយតាមឈ្មោះរបស់វា នៅពេលដែលទ្រង់ធ្វើបញ្ជីសារពើភ័ណ្ឌ នៅក្នុងទំនុកដំកើង ១៤៧:៤៖

> ទ្រង់រាប់ចំនួននៃអស់ទាំងផ្កាយ ក៏ហៅបានតាមឈ្មោះទាំងអស់

ការយកចិត្តទុកដាក់ផ្ទាល់របស់ព្រះអម្ចាស់ចំពោះការបង្កើតរបស់ទ្រង់ ត្រូវបានឃើញតាមរយៈការផ្តល់ឈ្មោះដល់ផ្កាយ ដែលជាសកម្មភាព ដែលបញ្ជាក់ពីអំណាចចេស្តារបស់ព្រះលើការបង្កើតរបស់ទ្រង់ (ប្រៀបធៀប លោកុ. ២:១៩-២០; ៣:២០)។

១.គ ការបង្កើតដោយប្រាជ្ញា

ទំនុកដំកើង ១៣៦:៥-៩
ទំនុកដំកើង ១០៤:២៤-២៦
ទំនុកដំកើង ១៤៥:១៧-២០
ទំនុកដំកើង ១៤៧:៣-៦

១.ឃ ការបង្កើតដោយព្រះចេស្តា

១.ង សម្រស់ និងភាសានៃការបង្កើត

១.ច ព្រះវត្តមាន និងការគ្រងរាជ្យបែបជាសកល

២. កិច្ចការរបស់ព្រះនៅក្នុងប្រវត្តសាស្ត្រអ៊ីស្រាអែល